ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# សាររំលែកមរណទុក្ខ

## គោរពជូន
## លោកជំទាវ ឈន ចន្ថា ព្រមទាំងក្រុមគ្រួសារ

**លោកជំទាវ ព្រមទាំងក្រុមគ្រួសារ ជាទីរាប់អានដ៏ជ្រាលជ្រៅ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ និងក្រុមការងារចុះជួយមូលដ្ឋានស្រុកបាភ្នំ មានសេចក្ដីក្ដុកក្ដួល និងសោកស្ដាយឥតឧបមា ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា **ឯកឧត្តម ហ៊ឹម សុផល** ជាសមាជិកក្រុមប្រឹក្សាខេត្ត និងជាអតីតប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រៃវែង បានទទួលមរណភាព នៅថ្ងៃអង្គារ ៣រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង១២:១៥នាទីថ្ងៃត្រង់ ក្នុងជន្មាយុ ៦៦ឆ្នាំ ដោយរោគាពាធ ។

ស្ថិតក្នុងវេលាដ៏សោកសង្រេង និងក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ និងក្រុមការងារចុះជួយមូលដ្ឋានស្រុកបាភ្នំ សូមចូលរួមសម្ដែងនូវសេចក្ដីសោកស្ដាយស្រណោះ អាឡោះអាល័យ ជាមួយ **លោកជំទាវ ព្រមទាំងក្រុមគ្រួសារ** ចំពោះការបាត់បង់ **ឯកឧត្តម ហ៊ឹម សុផល** ជាស្វាមី ជាឪពុក ជាឪពុកក្មេក និងជាជីតាប្រកបដោយព្រហ្មវិហារធម៌មិនចេះរីងស្ងួត និងសង្គហធម៌ដ៏ល្អប្រពៃរបស់ក្រុមគ្រួសារ ។

យើងខ្ញុំទាំងអស់គ្នា សូមចូលរួមរំលែកទុក្ខដោយសេចក្ដីសោកសង្រេងបំផុតជាមួយ **លោកជំទាវ ព្រមទាំងក្រុមគ្រួសារ** និងសូមសម្ដែងនូវការគោរពចំពោះដួងវិញ្ញាណក្ខន្ធរបស់ **ឯកឧត្តម ហ៊ឹម សុផល** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។

សូម **លោកជំទាវ ព្រមទាំងក្រុមគ្រួសារ** មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ ៕

ថ្ងៃ ពុធ ៤ រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០២២
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**និងជាប្រធានក្រុមការងារចុះមូលដ្ឋានស្រុកបាភ្នំ** ៤

ញ៉ឹម-សុខា